# លក្ខខន្តិកៈ

## ធានារ៉ាប់រងគ្រោះថ្នាក់បុគ្គលប៊ីម៉ា

### <u>នរណានឹងទទួលបានការធានា?</u>

ធានារ៉ាប់រងគ្រោះថ្នាក់បុគ្គល-ម្ចាស់បណ្ណ័សន្យារ៉ាប់រងត្រូវតែមាន ព័ត៌មានចុះឈ្មោះ នៅលើគោលការណ៍ ដើម្បីទទួលបានការធានានេះ។

### <u>អាយុ:</u>

អាយុដែលអាចធ្វើការចុះឈ្មោះសេវាកម្មនេះបានជាអប្បបរមាគឺចាប់ពី 18ឆ្នាំឡើងទៅ ។ មិនមានកំណត់អាយុអតិបរមាទេ។

### <u>ការកាត់ទឹកប្រាក់ និង ការធានា:</u>

- លក្ខខណ្ឌនៃការប្រើប្រាស់ ដើម្បីទទួលបានការធានាត្រូវបង់បុព្វលាភជាសាច់ប្រាក់នៅពេលចុះឈ្មោះជាមួយមន្ត្រីផ្នែកលក់របស់យើង។
- អត្ថប្រយោជន៍ពេញលេញនឹងទទួលបានភ្លាមៗបន្ទាប់ពីធ្វើការចុះឈ្មោះ។ ឧទាហរណ៍: បន្ទាប់ពីមានការបង់ទឹកប្រាក់បុព្វលាភពេញលេញរួចរាល់នៅថ្ងៃទី 20 ខែមករា សម្រាប់កញ្ចប់បីខែ, ការធានានឹងមានសុពលភាពរហូតដល់យប់រំលងអាធ្រាតថ្ងៃទី 20 ខែមេសា ឆ្នាំដដែល។ គ្មានការរង់ចាំដើម្បីទទួលបានការធានាលើផលិតផលនេះ។ ការចុះឈ្មោះ និងត្រូវធ្វើឡើងតាមរយៈប្រពន្ធ័អេឡិចត្រូនិកដែលដំណើរការតាមរយៈទូរស័ព្ទដៃ។

### <u>ការទាមទារសំណង:</u>

ការទាមទារសំណង អាចធ្វើទៅបានក្នុងរយៈពេល 3ខែក្នុងករណីមានគ្រោះថ្នាក់កើតឡើង ។ ដំណើរការផ្តល់សំណង នឹងផ្តល់បន្ទាប់ពីទទួលបានឯកសារខាងក្រោមបានគ្រប់គ្រាន់៖

- របាយការណ៍ប៉ូលិស រឺ លិខិតផ្លូវការពីមេភូម រឺ ចៅសង្កាត់ដែលមានសិទ្ធ
- កំណត់ហេតុគ្រូពេទ្យ រឺ វេជ្ជបណ្ឌិត
- ឯកសារបញ្ជាក់អត្តសញ្ញាណ
    - ឯកសារបញ្ជាក់អត្តសញ្ញាណដូចជា: អត្តសញ្ញាណបណ្ណ រឺ សៀវភៅគ្រួសារ បណ្ណ័បើកបរ រឺ លិខិតឆ្លងដែន
- ភស្តុតាងបញ្ជាក់ពីមរណៈភាពរួមមាន: លិខិតមរណៈភាព លិខិតបញ្ជាក់ពីគ្រូពេទ្យអំពីមូលហេតុនៃការស្លាប់ រឺ លិខិតផ្លូវការពីមេភូម រឺ ចៅសង្កាត់ដែលមានសិទ្ធ

- អតិថិជនអាចទំនាក់ទំនងមកក្រុមហ៊ុនប៊ីម៉ា តាមរយៈលេខទូរសព្ទ័ រឺក៏អាចមកក្រុមហ៊ុនផ្ទាល់ដើម្បីធ្វើការទាមទារសំណង។ មីលវីក(Milvik) នឹងធ្វើការផ្តល់សំណងយ៉ាងយូរបំផុតមិនឱ្យលើសពីរយៈពេល ៣ ថ្ងៃនៃថ្ងៃធ្វើការប្រសិនបើបានដាក់ឯកសារមកគ្រប់គ្រាន់ ។ ក្នុងករណីម្ចាស់បណ្ណ័សន្យារ៉ាប់រងទទួលមរណៈភាព សំណងនឹងត្រូវបានផ្តល់ជូនអ្នកទទួលផលសំណងដែលមានក្នុងគោលការណ៍ដោយផ្ទាល់ ។

## ករណីលើកលែងមិនផ្តល់សំណង:

ទឹកប្រាក់សំណងនឹងមិនត្រូវបានផ្តល់ជូន ប្រសិនបើហេតុការណ៍ណាមួយកើតឡើងដោយផ្ទាល់ រឺ ដោយប្រយោលបណ្តាលមកពី:

- ខណៈពេលម្ចាស់ប័ណ្ណសន្យារ៉ាប់រងស្ថិតនៅក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ឬថ្នាំញៀន ឬភាពឆ្កួតវង្វេង
- ដោយសារម្ចាស់ប័ណ្ណសន្យារ៉ាប់រងមានចេតនាបង្កគ្រោះថ្នាក់ បង្ករបួសស្នាមដោយខ្លួនឯង ឬចេតនាធ្វើសកម្មភាពឧក្រិដ្ឋកម្ម
- ក្នុងអំឡុងពេលព្យាបាល ឬវះកាត់
- ដោយសារសង្គ្រាម ការលុកលុយប្រទូសរាយពីសត្រូវបរទេស ការបះបោរសង្គ្រាមស៊ីវិល បដិវត្តន៍ កុប្បកម្មយោធា ឬការដណ្តើមអំណាច ឬចលាចលសង្គម
- ភាពអសមត្ថភាព ឬចុះខ្សោយរូបកាយដែលមានស្រាប់មុនពេលគ្រោះថ្នាក់ និងការចុះឈ្មោះ

## ការលុបចោលការធានា:

គោលការណ៍នៃការធានា អាចធ្វើការលុបចោលបានដោយធ្វើការទាក់ទងទៅកាន់ផ្នែកបម្រើសេវាអតិថិជនរបស់មីលវីក(Milvik) ឬមកកាន់ការិយាល័យក្រុមហ៊ុនមីលវីក(Milvik)ដើម្បីយកប្រាក់បង្វិល 90%វិញនៃប្រាក់បុព្វលាភដែលមិនបានគ្រោងទុក។